Ottawa County Health Department

# សន្លឹកព័ត៌មានសាធារណៈ

## ការពុលសាម៉ូណិល្លា [SALMONELLOSIS]

### តើការពុលសាម៉ូណិល្លាគឺជាអ្វី?

ការពុលសាម៉ូណិល្លា គឺជាការឆ្លងមេរោគក្នុងពោះវៀន បង្កដោយមេរោគដែលហៅថា “សាម៉ូណិល្លា” ដែលអាចធ្វើឱ្យកើតរាគ រមួលពោះ និងក្តៅខ្លួន។ ជម្ងឺមានរយៈពេលអស់ 4-7 ថ្ងៃ។ ទោះជាអ្នកភាគច្រើនជាដោយមិនបាច់ព្យាបាលក៏ដោយ ក៏អ្នកខ្លះ (ជាពិសេសកូនក្មេងតូច អ្នកចាស់ និងអ្នកមានប្រព័ន្ធស៊ាំជំងឺទន់ខ្សោយ) អាចឈឺខ្លាំងជាងទៅទៀត ហើយត្រូវការថ្នាំអង់ទីប៊ីយ៉ូទិក។

### តើសាម៉ូណិល្លាត្រូវបានឆ្លងតាមរបៀបអ្វីខ្លះ?

សាម៉ូណិល្លាអាចឆ្លងទៅមនុស្សដោយៈ

- អាហារដែលប្រឡាក់លាមកសត្វ
- សាច់ ឬស៊ុតដំឆៅ ឬស្ទើរឆ្អិន
- ផ្លែឈើ ឬ បន្លែ ដំមិនស្អាត
- អ្នកធ្វើម្ហូបដំមានជម្ងឺ ហើយមិនលាងដៃក្រោយពីបត់ជើង
- អ្នកចិញ្ចឹមសត្វលេង ដែលមិនលាងដៃក្រោយពីប៉ះសត្វរបស់គេ
- សត្វលូន ដូចជាសត្វអណ្តើក មានមេរោគសាម៉ូណិល្លាច្រើនជាងសត្វផ្សេង

### តើអាចមានរោគសញ្ញាអ្វីខ្លះ?

រោគសញ្ញាដំបូងនៃការពុលសាម៉ូណិល្លា កើតឡើងក្នុងរយៈពេលពី 12-72 ម៉ោងក្រោយពីពុលមេរោគ។

រោគសញ្ញាទូទៅ អាចមានៈ

- រាគអាចមំ
- ក្អួត/អារម្មណ៏ចង់ក្អួត
- រមួលពោះ
- ក្តៅខ្លួន
- ឈឺក្បាល

*អ្នកជម្ងឺសាម៉ូណិល្លាមួយចំនួនតិច នឹងឈឺសន្លាក់ឆ្អឹង ក្រហាយភ្នែក ហើយឈឺចាប់ពេលបត់ជើងតូច ដែលជម្ងឺនេះហៅថា រីទ័រ-ស៊ិនដ្រូម។ វាអាចមានអស់រយៈពេលរាប់ខែ ទៅរាប់ឆ្នាំ ហើយអាចនាំឱ្យកើតជម្ងឺហើមស្លាក់ឆ្អឹងរ៉ាំរ៉ៃ។*

### តើការពុលសាម៉ូណិល្លាត្រូវបានវិនិច្ឆ័យរោគយ៉ាងដូចម្តេច?

ការពុលសាម៉ូណិល្លាត្រូវបានវិនិច្ឆ័យរោគ តាមរយៈការពិនិត្យលាមក។ ជារឿយៗ ការពិនិត្យលាមកបន្តបន្ទាប់ត្រូវបានធ្វើឡើងដើម្បីបញ្ជាក់ពេលដែលអ្នកជម្ងឺអស់មេរោគហើយ។

### តើសាម៉ូណិល្លាត្រូវបានព្យាបាលយ៉ាងដូចម្តេច?

ធម្មតា ការពុលសាម៉ូណិល្លាជាក្នុងរយៈពេល 5-7 ថ្ងៃ។ ធម្មតា មិនត្រូវការថ្នាំអង់ទីប៊ីយ៉ូទិកទេ លើកលែងតែជម្ងឺរាលដាលពីពោះវៀនចូលក្នុងកន្លែងផ្សេងនៃរូបកាយ។ អ្នករាគខ្លាំងលើសលុប អាចត្រូវការបញ្ចូលទឹកស៊ីរ៉ូម បើសិនជាកើតកង្វះជាតិទឹកក្នុងខ្លួន។

### តើការពុលសាម៉ូណិល្លា អាចបង្ការបានយ៉ាងដូចម្តេច?

- កុំផឹកទឹកដោះគោឆៅទេ
- បោះចោលស៊ុតដំមានសំបកប្រេះ
- រៀបចំសាច់ និងស៊ុត ឱ្យដាច់ដោយឡែកពីអាហារផ្សេង
- លាងដៃបន្ទាប់ពីប៉ះសាច់ឆៅ
- ដុសលាងជ្រុញ តុចង្ក្រានបាយ និងឧបករណ៏ ដោយទឹកក្តៅសាប៊ូ ក្រោយពីវាប៉ះសាច់ និងស៊ុតឆៅ ឬស្ទើរឆ្អិន
- ចំអិនសាច់ និងស៊ុតទាំងស្រុង មុនបរិភោគ
- លាងដៃ និងដៃរបស់កូន បន្ទាប់ពីបត់ជើង ឬដូរកន្ទប មុនបរិភោគអាហារ ហើយក្រោយពីលេងជាមួយសត្វ

### សម្រាប់ព័តិមានបន្ថែមអំពីការពុលសាម៉ូណិល្លាទាក់ទងៈ

Ottawa County Health Department

www.miOttawa.org

Center for Disease Control and Prevention

www.bt.cdc.gov/

ទូរស័ព្ទ: (888) 246-2675

12251 James St., Suite 400
Holland, MI 49424

ទូរស័ព្ទ: (616) 396-5266
ទូរសារ: (616) 393-5643

វ៉ិបសាយ: www.miOttawa.org